# សុន្ទរកថាបើក
# របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# សិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង

រាជធានីភ្នំពេញ, ថ្ងៃអង្គារ ១៤ កើត ខែ ពិសាខ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧
ត្រូវនឹងថ្ងៃទី ២១ ខែ ឧសភា គ.ស. ២០២៤, សូហ្វីតែល ភ្នំពេញ ភូគីត្រា

*****+*****

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ថ្នាក់ដឹកនាំ, និង មន្ត្រីរាជការនៃក្រសួង-ស្ថាប័ន, ជាទីមេត្រី!**

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្តីសោមនស្សក្រៃលែង ដោយបានមកចូលរួមជាអធិបតីក្នុង**សិក្ខាសាលាផ្សព្វផ្សាយ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង** ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ជាថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៃក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ, ទាំងនៅទីនេះផ្ទាល់ និង ទាំងនៅពីចម្ងាយ, តាមប្រព័ន្ធអនឡាញ ។

ការរៀបចំតាក់តែង **អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង** អាចចាត់ទុកជាការបោះជំហានដ៏ត្រឹមត្រូវថ្មីមួយទៀត របស់រាជរដ្ឋាភិបាល ក្នុងកិច្ចប្រឹងប្រែងពង្រឹងមុខងារសវនកម្មផ្ទៃក្នុង ដើម្បីរួមចំណែកគាំទ្រដល់ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដែលបន្តផ្តល់អាទិភាពលើការពង្រឹងអភិបាលកិច្ច, ប្រសិទ្ធភាព,

ស័ក្តិសិទ្ធភាព, និង សមត្ថភាពនៃក្រសួង-ស្ថាប័ន តាមរយៈការបន្តអនុវត្តអភិក្រម **ផ្លុះកញ្ជក់, ងូតទឹក, ដុសក្អែល, ព្យាបាល**, និង **វះកាត់** ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!*

រាជរដ្ឋាភិបាលកម្ពុជា, ក្រោមការដឹកនាំ ប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, **អតីតនាយករដ្ឋមន្ត្រី**, និង បច្ចុប្បន្ន ជា **ប្រធានព្រឹទ្ធសភា**, បានរៀបចំផ្តួចផ្តើមដាក់ឱ្យអនុវត្ត នូវ «**កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**» ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង គ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈរបស់ជាតិ ។ កម្មវិធីនេះ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជា-ផ្លូវការ នៅថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចតេជោ** ក្នុងឋានៈ **សម្តេច ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាពេលនោះ ។ ចក្ខុវិស័យនៃកម្មវិធីកែទម្រង់នេះ គឺ៖ **ប្រែក្លាយប្រព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈកម្ពុជា ពីប្រព័ន្ធផ្តោតលើធាតុចូល និង មានលក្ខណៈមជ្ឈការ, ទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និង មានលក្ខណៈវិមជ្ឈការ, ស្របតាមស្តង់ដា និង ឧត្តមានុវត្តន៍អន្តរជាតិ** ។

ដើម្បីសម្រេចចក្ខុវិស័យខាងលើ, រាជរដ្ឋាភិបាល បានកំណត់យកយុទ្ធសាស្ត្រ បោះជំហានតាមដំណាក់កាល ឬ អភិក្រមជាខឿន ដែលក្នុងនោះ, កម្មវិធីកែទម្រង់នេះ ត្រូវបានបែងចែកជា ៤ ដំណាក់កាល រួមមាន៖ ដំណាក់កាលទី ១, ពីឆ្នាំ ២០០៤ ដល់ ២០០៨, ផ្តោតលើ **ការកសាងភាពជឿទុកចិត្តនៃថវិកា**; ដំណាក់កាលទី ២, ពីឆ្នាំ ២០០៩ ដល់ ២០១៥, ផ្តោតលើ **ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ**; ដំណាក់កាលទី ៣, ពីឆ្នាំ ២០១៦ ដល់ ២០២២, ផ្តោតលើ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**; និង ដំណាក់កាលទី ៤, ពីឆ្នាំ ២០២៣ ដល់ ២០២៧, ផ្តោតលើ **ការកសាងគណនេយ្យភាពសមិទ្ធកម្ម** ។ ក្នុងបរិបទនេះ, ដើម្បីគោលដៅនៃការពង្រឹងប្រសិទ្ធភាព, តម្លាភាព, និង គណនេយ្យភាពនៃកិច្ចប្រតិបត្តិការរបស់ស្ថាប័នរដ្ឋ, មុខងារសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតឡើង តាំងពីដំណាក់កាលទី ១ នៃការចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន, ក្រសួង, និង សហគ្រាសសាធារណៈ, ស្របតាមការកំណត់នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា, ដែលត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០០០ ។

ក្នុងរយៈពេលប្រមាណពីរទសវត្សរ៍កន្លងទៅនេះ, ជោគជ័យនៃការកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ ក៏ដូចជា ជោគជ័យនៃការកែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល ពិតជាបាននាំមកនូវវឌ្ឍនភាពល្អជាច្រើន និង បានឆ្លុះបញ្ចាំងឱ្យឃើញពីការវិវត្តទៅរកភាព កាន់តែប្រសើរឥតឈប់ឈរនៃកិច្ចប្រតិបត្តិការរបស់បណ្ដាក្រសួង-ស្ថាប័ន និង អង្គភាព សាធារណៈប្រហាក់ប្រហែល, លើគ្រប់ទិដ្ឋភាព រួមមាន៖ រចនាសម្ព័ន្ធស្ថាប័ន, មុខងារ, ប្រព័ន្ធ ដឹកនាំ, ប្រព័ន្ធគ្រប់គ្រង និង ប្រព័ន្ធត្រួតពិនិត្យ; និង ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស, រួមបញ្ចូលនូវ សមត្ថភាពជំនាញ, ទស្សនៈ, ផ្នត់គំនិត, វប្បធម៌នៃការបំពេញការងារ, ។ល។ ជាមួយនឹងវឌ្ឍនភាពដ៏ប្រសើរទាំងអស់នេះ, រាជរដ្ឋាភិបាល បានពិនិត្យឃើញថា អនុក្រឹត្យ លេខ ៤០ អនក្រ.បក ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដា ស្ថាប័ន, ក្រសួង, និង សហគ្រាសសាធារណៈ ដែលត្រូវបានរៀបចំតាំងពីឆ្នាំ ២០០៥, ទាំង ក្នុងទិដ្ឋភាពបទដ្ឋានគតិយុត្ត, ទិដ្ឋភាពបច្ចេកទេស និង វិសាលភាព, លែងអាចឆ្លើយតប បានពេញលេញ ទៅនឹងតម្រូវការការងារជាក់ស្ដែង នាបច្ចុប្បន្នទៀតហើយ, នេះម្យ៉ាង; ម្យ៉ាង ទៀត, ក៏ពុំអាចធានាបានគ្រប់ជ្រុងជ្រោយនៅឡើយ នូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, និង ចីរភាពនៃការធ្វើសវនកម្ម ដើម្បីគ្រប់គ្រងហានិភ័យផ្ទៃក្នុងនៃក្រសួង-ស្ថាប័ន ។

ក្នុងន័យនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដែលមានអគ្គនាយកដ្ឋានសវនកម្ម ផ្ទៃក្នុង ជាសេនាធិការ, បានផ្ដួចផ្ដើមធ្វើបច្ចុប្បន្នភាពអនុក្រឹត្យលេខ ៤០ អនក្រ.បក ស្ដីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្ដាស្ថាប័ន, ក្រសួង, និង សហ-គ្រាសសាធារណៈ ដើម្បីឆ្លើយតបទៅនឹងបរិការណ៍បច្ចុប្បន្នផង និង សម្រាប់រយៈពេល វែងទៅមុខផង ។ ទន្ទឹមនេះ, ដោយពិនិត្យឃើញថា ខ្លឹមសារដែលត្រូវកែលម្អ និង បំពេញ បន្ថែម មានច្រើន, ទើបក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យអគ្គនាយកដ្ឋាន សវនកម្មផ្ទៃក្នុង គិតគូររៀបចំជាអនុក្រឹត្យថ្មី ជំនួសអនុក្រឹត្យលេខ ៤០ អនក្រ.បក នេះ តែម្ដង; ស្របពេលដែលច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី, ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្ត កាលពីឆ្នាំ ២០២៣, ក៏បានកំណត់ឱ្យមានការរៀបចំនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និង សវនកម្ម ផ្ទៃក្នុង ផងដែរ ។ ជាលទ្ធផល, អនុក្រឹត្យលេខ ២៦៥ អនក្រ.បក ស្ដីពីការរៀបចំ និង ការ-ប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង, រួមមាន ៩ ជំពូក និង ១៧ មាត្រា, ត្រូវបានរាជរដ្ឋា-ភិបាល ដាក់ឱ្យអនុវត្ត នៅថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០២៣, ដោយបានកែសម្រួល និង បញ្ចូល បន្ថែមនូវចំណុចថ្មីសំខាន់ៗ ពីលើអនុក្រឹត្យលេខ ៤០ អនក្រ.បក, ដូច **ឯកឧត្តមបណ្ឌិត ជា**

**ឧទ្ធរណ៍**, ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ទើបបានរាយការណ៍ជូនអង្គប្រជុំជ្រាប នៅមុននេះបន្តិច ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

ពិតណាស់ថា ទោះបីជាអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង ថ្មីនេះ ត្រូវបានរៀបចំដោយគ្រប់ជ្រុងជ្រោយ ជាមួយនឹងការរំពឹងទុកថា អាចបម្រើ និង គាំទ្រដល់ការងារសវនកម្មផ្ទៃក្នុង បានប្រសើរជាងមុន ក៏ពិតមែន, ប៉ុន្តែ យើងក៏ទទួលស្គាល់ដែលថា អាចនៅមានកត្តាដទៃទៀតដែលបង្កជាហានិភ័យចំពោះគុណភាព និង ការសម្រេចបានជោគជ័យនៃការត្រួតពិនិត្យផ្ទៃក្នុងនេះ, ក្នុងនោះរួមមាន៖ កត្តាអត្តនោម័ត ឬ តួអង្គសំខាន់ចំនួន ៣ គឺ៖ ថ្នាក់ដឹកនាំកំពូលនៃក្រសួង-ស្ថាប័ន, សវនដ្ឋាន (អង្គភាពរងសវនកម្ម) និង សវនករ ។ តួអង្គទាំង ៣ មានទំនាក់ទំនងស្អិតល្មួតទៅវិញទៅមក, ហើយការអនុវត្តបានត្រឹមត្រូវនូវមុខងារ និង តួនាទីរបស់តួអង្គនីមួយៗ មានសារៈសំខាន់ក្នុងការទាញយកនូវអត្ថប្រយោជន៍ជាអតិបរមា ពីមុខងារសវនកម្មផ្ទៃក្នុងនេះ ។ ក្នុងន័យនេះ, ដើម្បីធានានូវប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និង ផលិតភាពការងារនៃតួអង្គទាំង ៣, ខ្ញុំសូមផ្តល់នូវអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

**ទី១-ថ្នាក់ដឹកនាំកំពូលនៃក្រសួង-ស្ថាប័ន** គឺជាតួអង្គគន្លឹះ ព្រោះថា ទោះបីជាសវនករពូកែ និង មានសមត្ថភាពខ្ពស់យ៉ាងណា និង សវនដ្ឋានបានសហការល្អកម្រិតណា ក៏ដោយ, ក៏ **អត្ថប្រយោជន៍ពិត** ពីសេវាសវនកម្មផ្ទៃក្នុង ពុំអាចកើតមានបានឡើយ ប្រសិនបើថ្នាក់ដឹកនាំកំពូលនៃក្រសួង-ស្ថាប័ន ដែលគ្រប់គ្រងផ្ទាល់ លើការងារសវនកម្មផ្ទៃក្នុង ពុំបានផ្តល់នូវការយកចិត្តទុកដាក់, ការគាំទ្រ និង ការគាំពារគ្រប់គ្រាន់ ។ អាស្រ័យហេតុនេះ, ដើម្បីទាញយកអត្ថប្រយោជន៍ពីការងារសវនកម្មផ្ទៃក្នុង ឱ្យបានជាអតិបរមា សម្រាប់ជាជំនួយដល់ការដឹកនាំ និង ការគ្រប់គ្រងក្រសួង-ស្ថាប័ននីមួយៗ, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ជាថ្នាក់ដឹកនាំ ត្រូវខិតខំស្វែងយល់អំពីសារៈសំខាន់ និង គុណប្រយោជន៍នៃកិច្ចការនេះ ឱ្យបានស៊ីជម្រៅ ដោយផ្តើមចេញពី, ម្យ៉ាង, ការស្វែងយល់អំពីអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ដែលត្រូវបានផ្សព្វផ្សាយ នាថ្ងៃនេះ, ក៏ដូចជា លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងទៀត; និង ម្យ៉ាងទៀត, ការពិនិត្យ និង ការអនុម័តលើផែនការយុទ្ធសាស្ត្រ និង ផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ, ការទទួលរបាយការណ៍សវនកម្ម, ការជំរុញការកែលម្អ

តាមអនុសាសន៍របស់សវនករ, ការពិគ្រោះ និង ការស្តាប់មតិយោបល់របស់ប្រធានក្រុមសវនកម្មផ្ទៃក្នុង ។ល។

**ទី២-សវនដ្ឋាន** ឬ **អង្គភាពរងសវនកម្ម** គឺជាតួអង្គដែលចូលរួមផ្ទាល់ ជាមួយសវនករ នៅក្នុងដំណើរការនៃការធ្វើសវនកម្មផ្ទៃក្នុង ប្រកបដោយប្រសិទ្ធភាព ។ ប្រការនេះទាមទារឱ្យសវនដ្ឋានទទួលស្គាល់ជាមុន នូវអត្ថប្រយោជន៍នៃកិច្ចការនេះ, ជាពិសេស ត្រូវប្រកាន់ខ្ជាប់នូវទស្សនៈវិជ្ជមាន ចំពោះសវនករដែលជាអ្នកមកជួយចង្អុលបង្ហាញនូវចំណុចខ្វះចន្លោះ ដើម្បីស្តាបនា និង កែលម្អ, ជាជាងការចាត់ទុកសវនករថា ជាអ្នកមកចាប់កំហុស និង ដាក់ទោសទណ្ឌ ។ ទន្ទឹមនេះ, សវនដ្ឋានគួរស្វែងយល់អំពីតួនាទី, ភារកិច្ច, នីតិវិធីសវនកម្ម, និង កាតព្វកិច្ចរបស់ខ្លួន ឱ្យបានច្បាស់លាស់ ដើម្បីធានាគុណភាព និង ប្រសិទ្ធភាពនៃការផ្តល់កិច្ចសហការ ព្រមទាំងត្រូវចូលរួមអនុវត្តនីតិវិធីសវនកម្ម ឱ្យបានទៀងទាត់ និង ពេញលេញ ដើម្បីបង្កភាពងាយស្រួល និង ទទួលបាននូវលទ្ធផលល្អពីការធ្វើសវនកម្មដែលមានតម្លៃបន្ថែមខ្ពស់សម្រាប់អង្គភាពរបស់ខ្លួន ។ សវនដ្ឋានក៏ត្រូវក្លាហាន ក្នុងការស្នើសុំបញ្ចូលបន្ថែម នូវទីសវនកម្ម (Audit Area) ដែលជាកង្វល់របស់ខ្លួន និង ដែលពុំមាននៅក្នុងផែនការសវនកម្ម ដើម្បីទទួលបាននូវអនុសាសន៍ជាដំណោះស្រាយ សំដៅលើកកម្ពស់ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពការងាររបស់ខ្លួន, និង ជាពិសេស ត្រូវខិតខំកែលម្អតាមអនុសាសន៍ដែលបានឯកភាពជាមួយសវនករ ។

**ទី៣-សវនករ** គឺជាតួអង្គសកម្ម, ហើយបើនិយាយភាសាសាមញ្ញ គឺជា **អ្នកដែងដល់** ។ ដូច្នេះ, សវនករត្រូវស្វែងយល់ឱ្យបានច្បាស់ នូវរាល់លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងជំនាញសវនកម្មផ្ទៃក្នុង, ជាពិសេស ត្រូវយល់ដឹងច្បាស់លាស់ អំពី តួនាទី, ភារកិច្ច, វិសាលភាព, សិទ្ធិ-អំណាច, សមត្ថកិច្ច, កាតព្វកិច្ច, នីតិវិធីសវនកម្ម ។ល។ ច្បាស់ណាស់ថា ដើម្បីក្លាយជាសវនករអាជីព, ការយល់ដឹងខាងលើនេះ នៅពុំទាន់គ្រប់គ្រាន់ទេ ។ បន្ថែមលើនេះ, សវនករត្រូវប្រកាន់ខ្ជាប់នូវឯករាជ្យភាព ក្នុងការបំពេញការងារដោយមិនលម្អៀង និង ត្រូវប្រកាន់ភ្ជាប់នូវភាពសត្យានុម័ត ក្នុងការវិភាគ និង ការវាយតម្លៃកិច្ចការ ដោយរក្សាភាពស្មោះត្រង់ និង មានចរិតស្ថាបនា នៅក្នុងការរាយការណ៍ ។ កត្តាទាំងនេះ គឺជាគុណតម្លៃដ៏វិសេសរបស់សវនករ ដែលត្រូវបានកំណត់នៅក្នុងក្រមសីលធម៌វិជ្ជាជីវៈសវនកម្មផ្ទៃក្នុង ។ ទន្ទឹមនេះ, សវនករក៏ត្រូវពង្រឹងសមត្ថភាពជាប្រចាំ, ទាំងជំនាញសវនកម្ម និង ចំណេះដឹងទូទៅ, គួបផ្សំនឹងចំណេះដឹងផ្នែកភាសាបរទេស និង បច្ចេកវិទ្យាព័ត៌មានផងដែរ, ពិសេស ចំណេះ និង ជំនាញទាំងឡាយ ដែលពាក់ព័ន្ធនឹងមុខងារ និង តួនាទីរបស់ក្រសួង-ស្ថាប័ន

របស់ខ្លួន ពីព្រោះ សវនករត្រូវធ្វើសវនកម្ម លើការបំពេញមុខងារ និង តួនាទីទាំងនោះ នៅពេលណាមួយ, ខណៈដែលចំណេះដឹងទូទៅទូលំទូលាយ នឹងជួយបន្ថែមដល់សវនករ ក្នុងការវិភាគបញ្ហា និង ការធ្វើសេចក្តីសន្និដ្ឋាន ឱ្យបានកាន់តែត្រឹមត្រូវ និង កាន់តែគ្រប់ជ្រុងជ្រោយ ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ខ្ញុំក៏សូមយកឱកាសដ៏កម្រនេះ ផ្តល់ការណែនាំបន្ថែមមួយចំនួនផងដែរ ដល់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដូចខាងក្រោម៖

១-ត្រូវខិតខំសម្របសម្រួលបញ្ចប់ការរៀបចំអនុក្រឹត្យស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលត្រូវបានកំណត់នៅក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០២៣ ឱ្យបានរួចរាល់ ទៅតាមកាលកំណត់ ពីព្រោះថា ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង គឺជាស្នូលសម្រាប់ការដឹកនាំ និង ការគ្រប់គ្រងផ្ទៃក្នុងរបស់អង្គភាពនីមួយៗ ។ ដូច្នេះ, អនុក្រឹត្យស្តីពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង នឹងក្លាយជាបង្គោលចរមួយថ្មីទៀតរបស់រាជរដ្ឋាភិបាល បន្ទាប់ពីអនុក្រឹត្យលេខ ២៦៥ នេះ ។

២-ត្រូវបន្តពង្រឹងសមត្ថភាពសវនករផ្ទៃក្នុងនៃក្រសួង-ស្ថាប័ន តាមរយៈការចុះពិនិត្យសុខភាពមុខងារសវនកម្មផ្ទៃក្នុង តាមក្រសួង-ស្ថាប័ន, ការបន្តផ្តល់ការណែនាំ, ការប្រឹក្សា និង កិច្ចពិភាក្សាអំពីបញ្ហាសវនកម្ម, ជាពិសេស ការបន្តរៀបចំវគ្គបណ្តុះបណ្តាល លើជំនាញសវនកម្ម និង ប្រភេទសវនកម្មថ្មី ដូចជា៖ សវនកម្មលើបច្ចេកវិទ្យាព័ត៌មាន, សវនកម្មលើសមិទ្ធកម្ម, សវនកម្មលើថវិកាយេនឌ័រ ។ល។ និង

៣-ត្រូវបន្តពង្រឹង និង ពង្រីកសមត្ថភាពរបស់ខ្លួន ក្នុងនោះ រួមមាន៖ ការពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង, ការបំពេញមូលដ្ឋានទិន្នន័យពហុបំណងសម្រាប់ការធ្វើសវនកម្ម, ពិសេសការធ្វើបរិវត្តកម្មនីតិវិធីសវនកម្ម ឱ្យកាន់តែស្វ័យប្រវត្តិ ជាដើម ។

**ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ចាប់តាំងពីសវនកម្មផ្ទៃក្នុង ត្រូវបានបង្កើតឡើង មកទល់បច្ចុប្បន្ន, ជារួម, ខ្ញុំពិនិត្យឃើញថា មុខងារនេះមានការរីកចម្រើន នៅគ្រប់ក្រសួង-ស្ថាប័ន ប៉ុន្តែត្បិតតែមានកម្រិតខុសគ្នាខ្លះក្តី ។ ខ្ញុំក៏ទទួលស្គាល់ដែរថា ការអនុវត្តមុខងារនេះមានការលំបាកស្មុគស្មាញ ដោយសារវាមានវិសាលភាពធំ និង ត្រូវការនូវពហុជំនាញផ្សេងគ្នា នៅតាមអង្គភាពក្រោមឱវាទក្រសួង-ស្ថាប័ន, នេះម្យ៉ាង; ម្យ៉ាងទៀត, ការបន្ថែមមុខងារថ្មី និង ការផ្លាស់ប្តូរផ្ទៃក្នុងនៃ

ក្រសួង-ស្ថាប័ន តែងកើតមានជារឿយៗ ដែលទាមទារឱ្យសវនករ ខិតខំស្វែងយល់អំពីការងារ និង ការផ្លាស់ប្តូរទាំងនោះ ឱ្យបានច្បាស់លាស់ និង គ្រប់ជ្រុងជ្រោយ ។ មួយវិញទៀត, សវនដ្ឋានមួយចំនួន អាចមិនឯកភាពលើអនុសាសន៍នៃការធ្វើសវនកម្មមួយចំនួន ដោយសារការវិភាគ, ការវាយតម្លៃ និង ការសន្និដ្ឋាន ត្រូវបានធ្វើឡើងដោយផ្អែកលើហានិភ័យ, ពោលគឺធ្វើឡើងនៅមុនបញ្ហាជាក់ស្តែង កើតឡើងទៅទៀត ។ យ៉ាងណាមិញ, ខ្ញុំសូមលើកទឹកចិត្តដល់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, សវនដ្ឋាន, ជាពិសេស សវនករផ្ទាល់, បន្តបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន ប្រកបដោយវិជ្ជាជីវៈ និង ការទទួលខុសត្រូវខ្ពស់, ដូចបានកំណត់នៅក្នុងអនុក្រឹត្យលេខ ២៦៥ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបានផ្សព្វផ្សាយ នាថ្ងៃនេះ ។

មុននឹងបញ្ចប់, ខ្ញុំសូមយកឱកាសដ៏ថ្លៃថ្លានេះ សម្តែងនូវអំណរគុណ និង ការកោតសរសើរ ដល់មន្ត្រីរាជការនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង, ជាពិសេស **ឯកឧត្តមបណ្ឌិត ជា ឌុធណា**, ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ដែលបានខិតខំលើកស្ទួយមុខងារសវនកម្មផ្ទៃក្នុង តាមក្រសួង-ស្ថាប័ន និង អង្គភាពនានា ចាប់តាំងពីដើមរៀងមក ។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ចំពោះសហការីនៃរាជរដ្ឋាភិបាល, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, និង អង្គភាពពាក់ព័ន្ធ ក្រោមឱវាទ ដែលបានផ្តល់ការគាំទ្រ និង ការចូលរួមអភិវឌ្ឍមុខងារសវនកម្មផ្ទៃក្នុង រហូតសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ដូចបច្ចុប្បន្ន ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ទាំងអ្នកដែលនៅទីនេះផ្ទាល់ និង ទាំងអ្នកដែលកំពុងតាមដាន តាមប្រព័ន្ធវីដេអូពីចម្ងាយ, បានប្រកបដោយពុទ្ធពរ និង ពរ ទាំង ៥ ប្រការ គឺ៖ **អាយុ, វណ្ណៈ, សុខៈ, ពលៈ** និង **បដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

ខ្ញុំសូមប្រកាសបើក **សិក្ខាសាលាផ្សព្វផ្សាយ អនុក្រឹត្យស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គភាពសវនកម្មផ្ទៃក្នុង** ចាប់ពីពេលនេះទៅ ៕

**សូមអរគុណ!**